# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកោះកុង**

សំណុំរឿងរដ្ឋប្បវេណីលេខ: ១៨

ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០

ឈ្មោះរឿងក្តី: ប្តឹងទាមទារឱ្យតុលាការប្រគល់អចលនវត្ថុ

សាលក្រមលេខ:......២៦.........(ង)

ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

## សាលក្រម
## គោរពនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកោះកុង

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ
នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២០ វេលាម៉ោង ១៧ និង ០០ នាទីរសៀល

### ចៅក្រមជំនុំជម្រះ

-លោក [redacted] ចៅក្រមសាលាដំបូងខេត្តកោះកុង

### ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកោះកុង

សាលាដំបូងខេត្តកោះកុង បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់នៅលើសំណុំរឿងរដ្ឋប្បវេណី លេខ:១៨ ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ដែលមានគូភាគីដូចខាងក្រោម៖

**-ដើមចោទ៖**

-ឈ្មោះ [redacted]លីហួត ភេទប្រុស អាយុ៤៣ឆ្នាំ ជនជាតិខ្មែរ មានអាសយដ្ឋាន[redacted]។

**-អ្នកតំណាងដោយអាណត្តិ៖**

-លោកមេធាវី [redacted] អត្តលេខ ២០១៤T និងលោកមេធាវី [redacted] អត្តលេខ ៩៧០ អាសយដ្ឋានអាគារលេខ៖ [redacted]។

**-ចុងចម្លើយ៖**

-ឈ្មោះ [redacted]វន ភេទប្រុស អាយុ៦៨ឆ្នាំ ជាតិខ្មែរ អាសយដ្ឋាននៅ[redacted]។

## អង្គហេតុ និងចំណុចវិវាទៈ

### ក.ខ្លឹមសារនៃការទាមទាររបស់ដើមចោទទាមទារឱ្យតុលាការចេញ

១.សូមអោយតុលាការបញ្ជាក់សិទ្ធិលើកម្មសិទ្ធិលើអចលនវត្ថុមានទំហំ ១៤000 ម៉ែត្រការ៉េ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ ចំពោះចុងចម្លើយឈ្មោះ [redacted] វន។

២.បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] វន ប្រគល់អចលនវត្ថុដែលមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ មកអោយដើមចោទឈ្មោះ [redacted] លីហ្វួត។

៣.បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] វន ធ្វើការរុះរើខ្ទមឈើប្រក់ស័ង្កសីចេញពីទីតាំងដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ មានបង្កាន់ដៃក្បាលដីលេខៈ ០៩០៤០១០៣(២០២២-២០២៣) ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ដែលមានទីតាំងដីស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

៤.ទាមទារឱ្យចុងចម្លើយឈ្មោះ [redacted] វន បង់ថ្លៃការខូចខាតពេលវេលា និងសំណងជំងឺចិត្តចំនួន ១០000 ដុល្លាមកឱ្យភាគីដើមចោទឈ្មោះ [redacted] លីហ្វួត។

### ខ.ដំណើររឿងក្តី និងចំណុចវិវាទ

#### ខ.១ ការសង្ខេបអំពីរឿងក្តី

កាលពីថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ដើមចោទឈ្មោះ [redacted] លីហ្វួត បានទទួលប្រទានកម្មលើអចលនវត្ថុមួយកន្លែងមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ មានទំហំ១,៤000 (មួយម៉ឺនបួនពាន់) ម៉ែតការ៉េ ពីឪពុកក្មេកឈ្មោះ [redacted] សារឿន និងម្តាយក្មេកឈ្មោះ [redacted] ហ៊ាង ផ្អែកតាមលិខិតអំណោយផ្តាច់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩។ ក្រោយមកចុងចម្លើយឈ្មោះ [redacted] វន បានមកអះអាងថាអចលនវត្ថុមួយកន្លែងនេះជារបស់ចុងចម្លើយឈ្មោះ [redacted] វន ដែលមានប្រភពមកពីអំណោយរបស់រដ្ឋ។

#### ខ.២ ចំណុចវិវាទ

តើអចលនវត្ថុដែលមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ជាកម្មសិទ្ធិរបស់ដើមចោទឈ្មោះ អ៊ួង លីហ៊ួត មែនដែរឬទេ?

#### ខ.៣ ការអះអាងរបស់ភាគីស្តីពីចំណុចវិវាទ

**ខ.៣.១.ស្តីពីចំណុចវិវាទ** តើអចលនវត្ថុដែលមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ ជាកម្មសិទ្ធិរបស់ដើមចោទឈ្មោះ [redacted] លីហ្វួត មែនដែរឬទេ?

-ការអះអាងរបស់ដើមចោទ៖ ៦

-អំពីអង្គហេតុ៖

កាលពីកំឡុងឆ្នាំ១៩៨៨ ឪពុកក្មេករបស់ខ្ញុំបាទឈ្មោះ [redacted] សារឿន និងម្ដាយក្មេកឈ្មោះ [redacted] ហ៊ាង បានមករស់នៅទីតាំងដីស្ថិតនៅភូមិព្រែកស្វាយ ឃុំសង្កាត់៣ ស្រុកទីរួមខេត្ត ខេត្តកោះកុង ហើយកាលពីដើមឆ្នាំ១៩៨៩ គណៈកម្មាធិការប្រជាជនកម្ពុជា បានធ្វើការចុះបញ្ជីដីធ្លីជាដើម្បីផ្ដល់ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ដីធ្លីចែកជូនប្រជាពលរដ្ឋនៅក្នុងភូមិ។ គណៈកម្មាធិការប្រជាជនរដ្ឋកម្ពុជា ក៏បានចែកចំការទំហំ ១៤000 ម៉ែត្រការ៉េ មកឱ្យឪពុកនិងម្ដាយក្មេករបស់កូនក្ដីខ្ញុំឈ្មោះ [redacted] សារឿន និងម្ដាយក្មេកឈ្មោះ [redacted] ហ៊ាង។

មួយឆ្នាំក្រោយមកប្រធានគណៈកម្មាធិការសុរិយោដីខេត្តកោះកុងឈ្មោះ [redacted] ប៊ុនឈឿន បានចេញប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ មកឱ្យឪពុកម្ដាយក្មេករបស់កូនក្ដីខ្ញុំដើម្បីធ្វើការកាន់កាប់ប្រើប្រាស់ និងអាស្រ័យផលទៅលើដីស្របតាមច្បាប់។

អំឡុងឆ្នាំ២០១៩ ឪពុកម្ដាយក្មេករបស់កូនក្ដីយើងខ្ញុំឈ្មោះ [redacted] សារឿន និងម្ដាយក្មេកឈ្មោះ [redacted] ហ៊ាង បានព្រមព្រៀងធ្វើប្រទានកម្មដីខាងលើមកឱ្យកូនក្ដីយើងខ្ញុំឈ្មោះ [redacted] លីហួត និងប្រពន្ធឈ្មោះ [redacted] ប៊ុនហេម តាមរយៈការធ្វើលិខិតអំណោយផ្ដាច់ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ដោយមានលោកចៅសង្កាត់ស្មាច់មានជ័យឈ្មោះ នាម យ៉ុង និងលោកមេភូមិ ០១ ឈ្មោះ [redacted] សារឿន ជាសាក្សីដឹងលឺ។

ក្រោយមកមន្ទីររៀបចំដែនដីនគររូបនីយកម្ម និងសំណង់បានធ្វើការវាស់វែងចុះបញ្ជីដីធ្លីជាប្រព័ន្ធដើម្បីរៀបចំកសាងវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុចែកជូនប្រជាពលរដ្ឋ ហើយក្រោយមកមន្ទីររៀបចំដែនដី នគររូបនីយកម្ម និងសំណង់ខេត្តកោះកុងបានចេញបង្កាន់ដៃក្បាលដីលេខ ០៩០៤០១០៣ ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២០ មកឱ្យកូនក្ដីយើងខ្ញុំជាម្ចាស់កម្មសិទ្ធិករ។

ក្រោយមកកូនក្ដីយើងខ្ញុំឈ្មោះ [redacted] លីហួត និងប្រពន្ធឈ្មោះ [redacted] ប៊ុនហេម បានមកចាក់ដីបំពេញ និងធ្វើរបងព័ទ្ធជុំវិញ ព្រមទាំងសាងសង់លំនៅដ្ឋានរស់នៅទីនោះ ស្រាប់តែឃើញឈ្មោះ [redacted] វន បានធ្វើសកម្មភាពរំលោភបំពានដោយកាប់ដើមឈើ បំផ្លិចបំផ្លាញដំណាំផ្សេងៗ និងដករបងព័ទ្ធជុំវិញថែមទាំងបានសាងសង់ផ្ទះខ្ទមឈើប្រក់ស័ង្កសីនៅលើដីកូនក្ដីយើងខ្ញុំ ស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដែលជាកម្មសិទ្ធិរបស់កូនក្ដីខ្ញុំ។

-អំពីអង្គច្បាប់៖

យោងតាមអនុក្រឹត្យស្ដីពីការគ្រប់គ្រងប្រើប្រាស់ដីធ្លីកសិកម្ម របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីនៃរដ្ឋកម្ពុជាលេខ៖ ០៦ អនក្រ ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៨៩ និងសេចក្ដីណែនាំអនុវត្តគោលនយោបាយគ្រប់គ្រង និងប្រើប្រាស់ដីធ្លីរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីកម្ពុជាលេខ៖០៣/សណន ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ១៩៨៩ ពលរដ្ឋកម្ពុជា មានសិទ្ធិពេញទីក្នុងការកាន់កាប់ប្រើប្រាស់ដីធ្លី និងមានសិទ្ធិអំណាចតំណមត៌កលើដីធ្លីដែលរដ្ឋប្រគល់ឱ្យសម្រាប់រស់នៅ និងធ្វើអាជីវកម្ម។ រដ្ឋធានាឱ្យអ្នកប្រើប្រាស់ដីធ្លីនូវសិទ្ធិកាន់កាប់ ប្រើប្រាស់និងទទួលផលស្របច្បាប់អំពីដីធ្លី។៦

ជាពិសេសរដ្ឋកម្ពុជាបានផ្តល់ជូនជាភោគៈលើផ្ទៃដីស្រែ ឬចម្ការជូនដល់គ្រួសារក្រីក្រ កសិករ ដើម្បីកាន់កាប់ប្រើប្រាស់ និងអាស្រ័យផល (ដីភោគៈ គឺជាដីដែលប្រជាពលរដ្ឋប្រគល់សិទ្ធិផ្តាច់មុខជូនដល់គ្រួសារកសិករកាន់កាប់ប្រើប្រាស់ក្នុងពេលធ្វើផលិតកម្ម អាជីវកម្ម និងបន្តមត៌ក)។

លើសពីនេះ តាមច្បាប់ភូមិបាល ឆ្នាំ២០០១ មាត្រា ៣០ ដែលដែលបានចែងថាបុគ្គលទាំងឡាយដែលបានអាស្រ័យផលនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ០៥ ឆ្នាំយ៉ាងតិច គិតមកដល់កាលបរិច្ឆេទនៃការប្រកាសឱ្យប្រើច្បាប់នេះលើអចលនវត្ថុ ដែលមានលក្ខណៈត្រឹមត្រូវតាមច្បាប់ក្នុងការកាន់កាប់ជាឯកជន មានសិទ្ធិស្នើសុំប័ណ្ណកម្មសិទ្ធិស្ថាពរ។

ក្នុងករណីដែលមានការជំទាស់ដល់ការផ្តល់ប័ណ្ណកម្មសិទ្ធិស្ថាពរនេះ អ្នកតវ៉ាត្រូវយកភស្តុតាងមកបញ្ជាក់ថាខ្លួនឯងផ្ទាល់បានបំពេញលក្ខខណ្ឌនៃភោគៈដោយសន្តិវិធី និងមិនមានការជំទាស់ចាប់ពី ៥ឆ្នាំនៅលើអចលនវត្ថុដែលមានទំនាស់ ឬយកភស្តុតាងដែលថាខ្លួនបានទិញអចលនវត្ថុនោះពីភោគៈដើម ឬពីសិទ្ធិវន្តស្របច្បាប់ ឬអ្នកទទួលផ្ទេរកម្មសិទ្ធិ ឬពីសន្តតិជនរបស់ខ្លួន។

ផ្អែកតាមមាត្រា ៥៦៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានចែងថាប្រទានកម្មសំដៅទៅលើកិច្ចសន្យាមួយដែលមានអានុភាពដោយភាគីម្ខាងបង្ហាញឆន្ទៈផ្តល់ទៅឱ្យភាគីម្ខាងទៀត នូវទ្រព្យសម្បត្តិដោយមិនយកថ្លៃ ហើយភាគីម្ខាងទៀតយល់ព្រមទទួល។

តាមផ្លូវច្បាប់នៅពេលដែលកូនក្តីយើងខ្ញុំ បានទទួលប្រទានកម្មហើយ កូនក្តីយើងខ្ញុំមានសិទ្ធិធ្វើលទ្ធកម្មនៃកម្មសិទ្ធិស្របតាមមាត្រា ១៦០ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលចែងថាកម្មសិទ្ធិលើអចលនវត្ថុ អាចត្រូវបានធ្វើលទ្ធកម្មដោយកិច្ចសន្យា សន្តតិកម្ម ព្រមទាំងតាមបញ្ញត្តិនៃក្រមនេះ ឬច្បាប់ផ្សេង។ មាត្រានេះបញ្ជាក់យ៉ាងច្បាស់លាស់ថាកូនក្តីយើងខ្ញុំ បានក្លាយជាម្ចាស់កម្មសិទ្ធិករបន្តប់ពីលទ្ធកម្មសិទ្ធិដោយការចុះបញ្ជី ស្របទៅតាមផ្លូវច្បាប់។

**-ការអះអាងរបស់ចុងចម្លើយ៖**

កាលពីអំឡុងឆ្នាំ១៩៨៩ ច្បាប់ក្រុមប្រឹក្សារដ្ឋមន្ត្រីបានឱ្យខ្ញុំបាទ និងចំនួន៤៧គ្រួសារ មករស់នៅខេត្តកោះកុងទីតាំងដីស្ថិតនៅឃុំស្ទឹងវែង។ ក្រោយពេលដែលពួកយើងខ្ញុំមកដល់ខេត្តកោះកុង ចៅហ្វាយស្រុកឈ្មោះ [redacted] ប៊ុថង លោកមេឃុំស្ទឹងវែងឈ្មោះ [redacted] វាន់ និងលោក [redacted] សាវ៉ារុធ ជាប្រធានគ្រប់គ្រងប្រជាជនព្រៃវែងដែលមករស់នៅខេត្តកោះកុង បានចែកដីមានទំហំ ក្បាល ៤០ ម៉ែត្រ និងបណ្តោយ ២០០ ម៉ែត្រ ដែលស្ថិតនៅឃុំស្ទឹងវែង ស្រុកដងទង់ ខេត្តកោះកុង ហើយរដ្ឋបានចិញ្ចឹមយើងខ្ញុំទាំង ៤៧ គ្រួសារ អស់រយៈពេល ៥ឆ្នាំ និងមានប្តូងអង្គភាពរួម ចំនួន ៣៥ គ្រួសារ ចំណែក ២៥ គ្រួសារទៀតបានត្រលប់ទៅវិញ។

## សំអាងហេតុ:

### ក.ស្តីពីចំណុចទទាន

ដើមចោទបានអះអាងអំពីសិទ្ធិកាន់កាប់ទៅលើអចលនវត្ថុដែលមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដោយផ្អែកទៅលើ ភស្តុតាងឯកសារគឺប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥និងលិខិតធ្វើអំណោយផ្តាច់ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៨។



Scanned with CamScanner

ចុងចម្លើយបានអះអាងអំពីសិទ្ធិកាន់កាប់ទៅលើអចលនវត្ថុដែលមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ប៉ុន្តែពុំមានភស្តុតាងជាឯកសារគតិយុត្តណាមួយដើម្បីបញ្ជាក់អំពីទំនាក់ទំនងនៃសិទ្ធិទៅលើអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះទេ។

ហេតុដូច្នេះហើយ តុលាការទទួលស្គាល់អត្ថិភាពនៃសិទ្ធិកាន់កាប់របស់ដើមចោទទៅលើអចលនវត្ថុដែលមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ដោយផ្អែកទៅលើ ភស្តុតាងឯកសារគឺប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥និងលិខិតផ្ទេរអំណោយផ្តាច់ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩។

## ខ.ការវិនិច្ឆ័យអំពីការទាមទារ

ផ្អែកតាមការធ្វើសេចក្តីថ្លែងការណ៍ និងការអះអាងរបស់គូភាគី ព្រមទាំងការពិនិត្យភស្តុតាងជាសម្ភារវិធី៖

**ខ.១.**យោងតាមឯកសារជាភស្តុតាង ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី ១៥ ខែមករា ឆ្នាំ១៩៩៥ និងកំណត់ហេតុស្តីពីលទ្ធផលចុះត្រួតពិនិត្យវាស់វែងដីធ្លី ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ តុលាការទទួលស្គាល់អត្ថិភាពនៃសិទ្ធិកាន់កាប់របស់ឈ្មោះ [redacted]សារឿន និងឈ្មោះ [redacted] ប៊ីកាងទៅលើអចលនវត្ថុដែលមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង ស្របតាមមាត្រា ២៩ និង មាត្រា ៣០ នៃច្បាប់ភូមិបាល។

**ខ.២.**ផ្អែកតាមលិខិតផ្ទេរអំណោយផ្តាច់អំណោយផ្តាច់ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលមានការចុះហត្ថលេខាបញ្ជាក់ពីលោកមេភូមិ០១ ឈ្មោះ [redacted] សារឿន និងលោកចៅសង្កាត់ស្មាច់មានជ័យឈ្មោះ [redacted] យ៉ុង តុលាការទទួលស្គាល់សុពលភាពនៃកិច្ចសន្យារបស់ភាគីនៅក្នុងកិច្ចសន្យាក្នុងការបង្ហាញឆន្ទៈព្រមព្រៀងផ្ទេរសិទ្ធិកាន់កាប់ចំពោះអចលនវត្ថុដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់លេខ: A3: 0170 ពីឈ្មោះ [redacted]សារឿន និងឈ្មោះ [redacted] ប៊ីកាង ទៅឱ្យឈ្មោះ [redacted] លីហ៊ួត និងឈ្មោះ [redacted] ប៊ុនហេង ផ្អែកតាមមាត្រា១៦០, មាត្រា៥៦៨ និងមាត្រា៥៦៩ នៃក្រមរដ្ឋប្បវេណី។

**ខ.៣.**ផ្អែកតាមលទ្ធផលនៃកំណត់ហេតុស្តីពីការចុះទៅពិនិត្យទីតាំងអចលនវត្ថុជាក់ស្តែង ដែលមានសមាសភាពចូលរួមគឺ លោកស្រី [redacted] វល័ក្ខ អនុការិយាល័យ តំណាងសាលាក្រុងខេមរភូមិន្ទ, លោក [redacted] សុភីរិទ្ធិ ប្រធានការិយាភូមិបាល ក្រុងខេមរភូមិន្ទ, លោក [redacted] យី ចៅសង្កាត់រងទី១ នៃសង្កាត់ស្មាច់មានជ័យ, លោក [redacted] សារឿនមេភូមិ០១ បានចង្អុលបង្ហាញថាទីតាំងអចលនវត្ថុដែលជាកម្មវត្ថុវិវាទផ្អែកតាមប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ ពិតជាស្ថិតនៅទីតាំងនោះមែន ហើយក៏មានការចូលរួមពីភាគីដើមចោទ និងចុងចម្លើយផងដែរ។

**ខ.៤.**ផ្អែកតាមសំអាងហេតុ ខ.១, ខ.២, ខ.៣ តុលាការទទួលទទួលស្គាល់អត្ថិភាពនៃសិទ្ធិកាន់កាប់របស់ដើមចោទ ដោយភាគីដើមចោទបានទទួលបន្តនូវសិទ្ធិ និងកាតព្វកិច្ចចំពោះអចលនវត្ថុដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ ពីឈ្មោះ [redacted]សារឿន និងឈ្មោះ [redacted] ប៊ីកាង ដែលបានកាន់កាប់ស្របច្បាប់តាំងពីឆ្នាំ ១៩៩៥។៦



Scanned with CamScanner

ខ.៥.ផ្អែកតាមការអះអាងរបស់ភាគីចុងចម្លើយអំពីទំនាក់ទំនងនៃសិទ្ធិចំពោះអចលនវត្ថុ ចុងចម្លើយពុំមានឯកសារគតិយុត្តិណាមួយដើម្បីបង្ហាញអំពីអត្ថិភាពនៃសិទ្ធិទៅលើអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះទេ យល់ឃើញចុងចម្លើយពុំមានទំនាក់ទំនងគតិយុត្តស្របច្បាប់ទៅលើអលចនវត្ថុដែលជាកម្មវត្ថុវិវាទនោះទេ ហេតុដូច្នេះតុលាការពុំទទួលស្គាល់ការអះអាងរបស់ចុងចម្លើយអំពីអត្ថិភាពនៃសិទ្ធិចំពោះអចលនវត្ថុដែលជាកម្មវត្ថុវិវាទនោះទេ។

ខ.៦.ផ្អែកតាមការអះអាងរបស់ភាគីនៅក្នុង សំណុំរឿងចុងចម្លើយបានទទួលស្គាល់ថាខ្លួនបានសាងសង់ផ្ទះខ្ទមនៅលើដីដែលជាកម្មវត្ថុវិវាទពិតប្រាកដមែន តុលាការយល់ឃើញថាចុងចម្លើយពុំមានអត្ថិភាពនៃសិទ្ធិចំពោះអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះទេ ហេតុដូច្នេះចុងចម្លើយមិនមានសិទ្ធិក្នុងការសាងសង់ផ្ទះខ្ទមនៅលើអចលនវត្ថុដែលជាកម្មសិទ្ធិរបស់អ្នកដទៃនោះទេ។

ខ.៧.តាមការអះអាងរបស់ដើមចោទអំពីការខូចខាតទៅពេលវេលា និងជំងឺចិត្តចំនួន ១០០០០ (មួយម៉ឺន) ដុល្លា យល់ឃើញថាជាគោលការណ៍ការខូចខាតត្រូវសងជាប្រាក់ ផ្អែកតាមមាត្រា ៧៤៧ ប៉ុន្តែដើមចោទពុំបានបង្ហាញនូវភស្តុតាងបញ្ជាក់ច្បាស់លាស់អំពីទំហំនៃការខូចខាតទៅលើពេលវេលាថាការខូចខាតនោះមានអ្វីខ្លះ ហើយទំហំនៃការខូចខាតពេលវេលានោះមានចំនួនប៉ុន្មាន ដោយដើមចោទបានលើកឡើងតែការខូចខាតផ្នែកសម្ភារៈតែប៉ុណ្ណោះ ដូច្នេះ គប្បីតុលាការពិចារណាអំពីទំហំនៃសំណងអោយបានសមរម្យទៅតាមភស្តុតាងដែលដើមចោទដាក់ជូនតុលាការ។ ម្យ៉ាងវិញទៀតអំពីការទាមទារចំពោះសំណងជំងឺចិត្ត តុលាការយល់ឃើញថានៅក្នុងរឿងក្តីដែលវិវាទអំពីសិទ្ធិកម្មសិទ្ធិចំពោះអចលនវត្ថុផ្អែកតាមស្មារតីនៃមាត្រា ៤០០ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី គឺអត្ថិភាពនៃសិទ្ធិក្នុងការទាមទារសំណងជំងឺចិត្តធ្វើបានក្នុងករណីមានការបំពានទៅដល់ផលប្រយោជន៍បុគ្គលដូចជា កេរ្តិ៍ឈ្មោះ អាយុជីវិត រូបរាងកាយជាដើម ចំណែកឯការខូចខាតជាទ្រព្យសម្បត្តិ ប្រសិនបើមានការធ្វើបដិទានឡើងវិញនូវទ្រព្យសម្បត្តិនោះហើយនោះការឈឺចាប់ខាងផ្លូវចិត្តក៏ត្រូវបានជួសជុល និងបដិទានឡើងវិញដែរ ហេតុដូច្នេះគប្បីតុលាការច្រានចោលការទាមទាររបស់ដើមចោទចំពោះសំណងជំងឺចិត្ត។

**គ.ការវិនិច្ឆ័យអំពីប្រាក់ប្រដាប់ក្តី**

យល់ឃើញថាប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយស្របតាមមាត្រា៦៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## ហេតុដូច្នេះសម្រេច:

១-/បញ្ជាក់ថាដើមចោទមានសិទ្ធិលើកម្មសិទ្ធិលើអចលនវត្ថុមានទំហំ ១៤០០០ ម៉ែត្រការ៉េ ដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ ចំពោះចុងចម្លើយឈ្មោះ [redacted] វន។

២-/បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] វន ប្រគល់អចលនវត្ថុដែលមានទីតាំងនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង មានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ ១៩៩៥ មកអោយដើមចោទឈ្មោះ [redacted] លីហួត។

៣-/បង្គាប់អោយចុងចម្លើយឈ្មោះ [redacted] វន ធ្វើការរុះរើខ្ទមឈើប្រក់ស័ង្កសីចេញពីទីតាំងដីដែលមាន ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ A3: 0170 ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៩៩៥ មានបង្គោលព្រំ

លេខ: ០៩០៤០១០៣(២០២២-២០២៣) ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ដែលមានទីតាំងដីស្ថិតនៅភូមិ០១ សង្កាត់ស្មាច់មានជ័យ ក្រុងខេមរភូមិន្ទ ខេត្តកោះកុង។

៤-/បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] វន បង់ថ្លៃការខូចខាតចំនួន ៥០០០ (ប្រាំពាន់) ដុល្លាមកឱ្យដើមចោទឈ្មោះ [redacted] លីហួត។

៥-/ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

-សាលក្រមនេះប្រកាសជាសាធារណៈ នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០។ ៚

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និងត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា [redacted]

---

**បានចម្លងត្រឹមត្រូវតាមច្បាប់ដើម**

ថ្ងៃចន្ទ ០៣ រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

កោះកុង,ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

កោះកុង,ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០២០

**ចៅក្រមជំនុំជម្រះ**

[redacted]